ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៩១៩
ចុះថ្ងៃទី០៦-០៨-២០១៨

**សាលដីកា**
លេខ : ២៤ក្រV "វ"
ចុះថ្ងៃទី ១៩-០៤-២០១៩

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ : នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-០៧-២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ នាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ ដោយមាន ៖

<u>សមាសភាពក្រុមប្រឹក្សា</u>

លោក [redacted] ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា
លោកស្រី [redacted] ចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

លោក [redacted] ព្រះរាជអាជ្ញា

<u>ក្រឡាបញ្ជី</u>

លោក [redacted]

ដើម្បីជំនុំជម្រះលើរឿងព្រហ្មទណ្ឌលេខ : ៩១៩ ចុះថ្ងៃទី០៦-០៨-២០១៨ ដែលមាន ៖

១-ពិរុទ្ធជនឈ្មោះ អ៊ិនវ៉ូកូ ព្រីហ្វ្រីស ឈីនីមេ (Nwoko [redacted]) ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិនីហ្សេរីយ៉ា កើតនៅប្រទេសនីហ្សេរីយ៉ា ទីលំនៅមុនពេលឃាត់ខ្លួន ផ្ទះជួលលេខ១៧B ផ្លូវ ៥១០ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ Samuel Uche Mex "វ" ម្តាយឈ្មោះ Opolonia Nwoko "វ" (នៅលីវ) ។

-ឃុំខ្លួននៅថ្ងៃទី២៤-០៩-២០១៣ នៅពន្ធនាគារម១) ។

២-ពិរុទ្ធជនឈ្មោះ ថេល័រ យូសេ អាន (Taylor [redacted] ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិអូស្ត្រាលី មុខរបរគ្រូបង្រៀន កើតនៅប្រទេសអូស្ត្រាលី ទីលំនៅមុនពេលឃាត់ខ្លួន ផ្ទះ

លេខ ៣៣ ផ្លូវ Buckingham ក្រុង Mt Hallen Queensland Austalia ឪពុកឈ្មោះ Barry Taylor "រ" ម្តាយឈ្មោះ Marlene Wilson "រ" ប្តីឈ្មោះ Harley Young (លែងលះ) ។ ឃុំខ្លួននៅថ្ងៃទី២៤-០៩-២០១៣ នៅពន្ធនាគារ ត្រពាំងថ្លុង (PJ) ។

៣-ពិរុទ្ធជនឈ្មោះ សាវ៉ារីណូ ហ្វាលីន (Savarino [redacted]) ភេទស្រី អាយុ១៩ឆ្នាំ ជនជាតិបារាំង មុខរបរធ្វើការនៅភោជនីយដ្ឋាន LaDuo កើតនៅប្រទេសបារាំង ទីលំនៅមុនពេលឃាត់ខ្លួន ផ្ទះលេខ ១៤ ផ្លូវលេខ ៥៩ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ (នៅលីវ) ឪពុកឈ្មោះ Luigi Savarino "ស" ម្តាយឈ្មោះ Sylvie Rousselle "រ" ។ ឃុំខ្លួននៅថ្ងៃទី២៤-០៩-២០១៣ នៅពន្ធនាគារម២ ។

៤-ពិរុទ្ធជនឈ្មោះ Ojukwu [redacted] ហៅ NTO ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិនីហ្សេរីយ៉ា (Nigerian)កើតនៅ Onitsha ប្រទេសនីហ្សេរីយ៉ា ទីលំនៅផ្ទះលេខលេខ ១A ផ្លូវលេខ២៥BT ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាន់លិខិតឆ្លងដែនលេខ A04657209 ។ (គេចខ្លួន)

៥-ពិរុទ្ធជនឈ្មោះ Asemota [redacted] ភេទប្រុស ជនជាតិនីហ្សេរីយ៉ា កើតនៅក្រុងបេនីន ប្រទេសនីហ្សេរីយ៉ា (Benin city , Nigeriya ) កាន់លិខិតឆ្លងដែនលេខ A01170452 ។ (គេចខ្លួន)

ជាប់ចោទពីបទ: **ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន (ឆ្លងដែន)** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ដល់ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-មានលោកមេធាវី [redacted] ការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ ថេល័រ យូសេអាន ។

-មានអ្នកបកប្រែឈ្មោះ [redacted] ភេទប្រុស មានអាស័យដ្ឋាននៅភូមិត្រពាំងល្ពៅ ឃុំជយោ ស្រុកចំការលើ ខេត្តកំពង់ចាម ឲ្យពិរុទ្ធជន ថេល័រ យូសេ អាន ។

**<u>៦រឿងហេតុមានដូចតទៅ</u> ៖**

នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣ សមត្ថកិច្ចប្រទេសអូស្ត្រាលីបានធ្វើការចាប់ខ្លួនជនជាតិអូស្ត្រាលីឈ្មោះ Cathryn [redacted] ភេទប្រុស អាយុ៤៤ឆ្នាំ និងឈ្មោះ David [redacted] ភេទប្រុស អាយុ៤២ឆ្នាំ នៅប្រទេសអូស្ត្រាលី ដកហូតបានម្សៅហេរ៉ូអ៊ីន ចំនួន ០៨គីឡូក្រាម ដែលជនល្មើសទាំងពីរបានទទួលពីជនត្រូវចោទឈ្មោះ Nwoko

[redacted] ពីប្រទេសកម្ពុជា ។ បន្ទាប់មកសមត្ថកិច្ចប្រទេសអូស្ត្រាលីបានផ្តល់ព័ត៌មានមកនាយកដ្ឋានគេរវកម្មក្រសួងមហាផ្ទៃ ។ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ ឈ្មោះ Ojukwu [redacted] ហៅ NTO បានយកកាបូបស្ពាយមួយឲ្យជនត្រូវចោទឈ្មោះ Nwoko [redacted] នៅផ្ទះជួល១៧B ផ្លូវ៥១០ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ដើម្បីប្រគល់ឲ្យឈ្មោះ Jonh ភេទប្រុស សញ្ជាតិអូស្ត្រាលីនៅ Brishane ប្រទេសអូស្ត្រាលី ។ នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ វេលាម៉ោង១១និង៣០នាទីព្រឹក ឈ្មោះ Nwoko [redacted] បានប្រគល់កាបូបស្ពាយខាងលើទៅឲ្យឈ្មោះ Savarino [redacted] ប្រគល់បន្តឲ្យទៅជនត្រូវចោទឈ្មោះ Taylor [redacted] យកទៅប្រទេសអូស្ត្រាលីតាមច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ។ ពេលដែលជនត្រូវចោទឈ្មោះ Savarino [redacted] និង Taylor [redacted] យកកាបូបចូលទៅក្នុងអាកាសយានដ្ឋានអន្តជាតិភ្នំពេញ ក៏ត្រូវសមត្ថកិច្ចធ្វើការចាប់ខ្លួនអ្នកទាំងពីរព្រមទាំងឆែកឆេរកាបូបស្ពាយខាងលើរកឃើញម្សៅហេរ៉ូអ៊ីនទម្ងន់ ២០០៤.៤០ ក្រាម និងបន្តចាប់ខ្លួនឈ្មោះ Nwoko [redacted] លុះក្រោយពេលចៅក្រមស៊ើបសួររួចមករកឃើញឈ្មោះ Asemta [redacted] ហៅ Justrice Edo ភេទប្រុស ជនជាតិនីហ្សេរីយ៉ា មានជាប់ពាក់ព័ន្ធក្នុងការទទួលគ្រឿងញៀននិងផ្ញើរលុយឲ្យឈ្មោះ Nwoko [redacted] ។

**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ **៥០៩ចម២** **"ឆ"** ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ផ្តន្ទាទោស ៖

ក.ឈ្មោះ Nwoko [redacted] ភេទប្រុស អាយុ២៣ឆ្នាំ ជាតិនីហ្សេរីយ៉ា (Nigeriya) ដាក់ពន្ធនាគារកំណត់ចំនួន ២៧ (ម្ភៃប្រាំពីរ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន)រៀល ។

ខ.ឈ្មោះ Savarino [redacted] ភេទស្រី អាយុ១៩ឆ្នាំ ជនជាតិបារាំង ដាក់ពន្ធនាគារកំណត់ចំនួន២៥ (ម្ភៃប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០.០០០.០០០ (ហាសិបលាន)រៀល ។

គ.ឈ្មោះ Taylor [redacted] ភេទស្រី អាយុ៤១ឆ្នាំ ជាតិអូស្ត្រាលី ដាក់ពន្ធនាគារកំណត់ចំនួន២៣ (ម្ភៃបី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០.០០០.០០០ (ហាសិបលាន)រៀល ។

ឃ.ឈ្មោះ Ojukwu [redacted] ហៅ NTO ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិនីហ្សេរីយ៉ា ដាក់ពន្ធនាគារកំណត់ចំនួន ២៧ (ម្ភៃប្រាំពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន)រៀល ។

ង.ឈ្មោះ Asemota [redacted] ភេទប្រុស ជាតិនីហ្សេរីយ៉ា ដាក់ពន្ធនាគារកំណត់ចំនួន ២៧ (ម្ភៃប្រាំពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន៨០.០០០.០០០ (ប៉ែតសិបលាន)រៀល ។

ពីបទ: ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន (ឆ្លងដែន) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៤០នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២.ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ Ojukwu [redacted] ហៅ NTO និងឈ្មោះ Asemota [redacted] យកមកទទួលទោសតាមអំណាចសាលក្រមនេះ តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣.វត្ថុតាងដូចមាននៅក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ៥៩២ វ.ត ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ ២០១៣ របស់ឃ្លាំងតម្កល់វត្ថុតាងរបស់សាលាដំបូងរាជធានីភ្នំពេញ រួមមាន ៖

ក.ហឹបដែកពណ៌សបិទជិត មានហត្ថលេខាគណៈកម្មការចូលរួមធ្វើការវេចខ្ចប់វត្ថុតាងនិងស្នាមមេដៃរបស់ជនសង្ស័យ ។ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ១៧៦៩ អ.យ.ង ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០១៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បញ្ជាក់ថាម្សៅហេរ៉ូអ៊ីនទម្ងន់ ២០០២,៤០ (ពីរពាន់ពីរក្បៀសសែសិប)ក្រាម ។

ខ.ក្រដាសពណ៌ក្រហមវេចខ្ចប់គ្រឿងញៀន និងកាបូបស្ពាយពណ៌ខ្មៅមួយ ។ ត្រូវរឹបអូស ។

គ.ទូរស័ព្ទដៃម៉ាក HTC ពណ៌ខ្មៅមួយគ្រឿង, ទូរស័ព្ទដៃម៉ាក HUAWEI ពណ៌សមួយគ្រឿង, ទូរស័ព្ទម៉ាកសាំសុង GALAXY ពណ៌សមួយគ្រឿង និងទូរស័ព្ទដៃម៉ាកសាំសុងស៊េរីចាស់គ្មានថ្មចំនួនមួយគ្រឿង ។

ឃ.លិខិតឆ្លងដែនរបស់ឈ្មោះ Nwoko [redacted] លេខ A01722 130 ។

ង.លិខិតឆ្លងដែនរបស់ឈ្មោះ Nwoko [redacted] លេខ A01047063 ។

ច.លិខិតឆ្លងដែនរបស់ឈ្មោះ Taylor [redacted] លេខ A4277246 ។

ឆ.ម៉ូតូម៉ាក AIR BLADE ពណ៌ខ្មៅ ពាក់ស្លាកលេខភ្នំពេញ 1AB 5138 មួយគ្រឿង ។

ជ.រថយន្តម៉ាក CILECA ពណ៌ស ពាក់ស្លាកលេខភ្នំពេញ 2C 3335 ចំនួនមួយគ្រឿង ។

ឈ.កុំព្យូទ័រយួរដៃម៉ាក ASUS ពណ៌ខ្មៅមួយគ្រឿង ។

ញ.កាបូបដៃចាស់ៗ ០២ ។

ដ. លោហធាតុពណ៌សមួយចំនួន (ខ្សែក ក្រវិល...) ។

ឋ.ឯកសារមួយចំនួន ។

ឌ.ឧបករណ៍អេឡិចត្រូនិចពណ៌ខ្មៅចំនួន០២គ្រឿង ។

ឍ.កុំព្យូទ័រដៃម៉ាក La Vie ពណ៌សមួយគ្រឿង ។

ណ.ឧបករណ៍សម្រាប់សាកថ្ម មួយចំនួន ។

ត.ឧបករណ៍ម៉ាក Hard Drive by HITACHI ចំនួន០១គ្រឿង ។

ថ.នាឡិកាដៃមួយចំនួន ០៦គ្រឿង ។

ទ.ប្រាក់ដុល្លាអាមេរិកចំនួន៤៦១ដុល្លា(បួនរយហុកសិបមួយ) ដុល្លាអាមេរិក

ធ.កាបូបស្ពាយសម្រាប់ដាក់កុំព្យូទ័រយួរដៃ០១ ។

ន.វ៉ាលីដាក់ខោអាវ ០២ ។

ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទឈ្មោះ Nwoko [redacted] , ជនជាប់ចោទឈ្មោះ Taylor Y[redacted] ,ជនជាប់ចោទឈ្មោះ Savarino Charlene កំបាំងមុខជនជាប់ចោទឈ្មោះ Ojukwu [redacted] ហៅ NTO និងជនជាប់ចោទឈ្មោះ Asemta J[redacted] បើកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-**បានឃើញ** បណ្ដឹងឧទ្ធរណ៍លេខ ៣៣៤ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ របស់ឈ្មោះ Precious [redacted] ប្ដឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៥០ កប២ "ឆ" ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច ១ នៃសេចក្ដីសម្រេចទាំងមូល ។

-**បានឃើញ** បណ្ដឹងឧទ្ធរណ៍លេខ ៣៦១ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ របស់ឈ្មោះ Yoshe [redacted] ប្ដឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៥០កប២ "ឆ"

ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

**-បានឃើញ** បណ្តឹងឧទ្ធរណ៍លេខ៣៦៣ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] មេធាវីការពារសិទ្ធិឲ្យឈ្មោះ Charlene [redacted] ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ៥០កប២"ឥ" ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច១"ខ"នៃសេចក្តីសម្រេចទាំងមូល ។

**-បានឃើញ** សាលដីកាព្រហ្មទណ្ឌលេខ១១៨"ក្រVបស" ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៣៤ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ Nwoko [redacted] , បណ្តឹងឧទ្ធរណ៍លេខ ៣៦១ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ របស់ឈ្មោះ Taylor [redacted] និងបណ្តឹងឧទ្ធរណ៍លេខ៣៦៣ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ Savarino [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥០កប២"ឥ"ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៣.បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទឈ្មោះ Nwoko [redacted] ឈ្មោះ Taylor [redacted] និងជនជាប់ចោទឈ្មោះ Savarino [redacted] និងប្រកាសជាសាធារណៈនៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទឈ្មោះ Nwoko [redacted] , ឈ្មោះ Taylor [redacted] ,ឈ្មោះ Savarino [redacted] ។ បើកសិទ្ធិប្តឹងសាទុក្ខ តាមកំណត់ច្បាប់ ។

**-បានឃើញ** បណ្តឹងសាទុក្ខលេខ ៤៥៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់ឈ្មោះ Nwoko [redacted] ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១១៨ "ក្រVបស" ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

**-បានឃើញ** បណ្តឹងសាទុក្ខ ០៩ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧ របស់ឈ្មោះ Taylor [redacted] ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ១១៨ "ក្រVបស" ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

-**បានឃើញ** សាលដីកាព្រហ្មទណ្ឌលេខ ៣១៨ ចុះថ្ងៃទី១៣-០៧-២០១៨ របស់តុលាការកំពូល ដែលបានសម្រេចបញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ៧១ ចុះថ្ងៃទី១៦-០៣-២០១៧ របស់តុលាការកំពូល មកសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះឡើងវិញលើឈ្មោះ ថេល័រ យូសេ អាន ។

-**បានឃើញ** របាយការណ៍សង្ខេបសំណុំរឿង របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ចុះថ្ងៃទី ១១-១២-២០១៨ ។

-**បានឃើញ** សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍ ចុះថ្ងៃទី២០-០២-២០១៩ ។

-**បានឃើញ** ពាក្យសុំបញ្ចូលឯកសារភស្តុតាង ចុះថ្ងៃទី២៥-០៣-២០១៩ របស់មេធាវី សូ មូស្សេន្ទី ការពារសិទ្ធិឲ្យពិរុទ្ធជន ថេល័រ យូសេ អាន ។

-**បានឃើញ** ពាក្យសុំដាក់បញ្ចូលសេចក្តីសន្និដ្ឋានផ្ទាល់មាត់ជាលាយលក្ខអក្សរ ចុះថ្ងៃទី២៧-០៣-២០១៩ របស់មេធាវី សូ មូស្សេន្ទី ការពារសិទ្ធិឲ្យពិរុទ្ធជន ថេល័រ យូសេ អាន ។

**<u>នាពេលសវនាការ</u>**

- ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿងក្តី
- ពិរុទ្ធជនឈ្មោះ ថេល័រ យូសេអាន (វត្តមាន)
- មេធាវី [redacted]ការពារសិទ្ធិឲ្យជនជាប់ចោទ (វត្តមាន)

-ពិរុទ្ធជនឈ្មោះ ថេល័រ យូសេអាន បានឆ្លើយថា ៖ រឿងនេះកើតឡើងនៅឆ្នាំ២០១៣ ។ ខ្លួនស្គាល់ឈ្មោះ អ៊ិនវូក្វ ព្រីហ្សីស តាំងពីឆ្នាំ២០១៣ តាមប្រព័ន្ធអ៊ិនធឺណែត Website សម្រេចណាត់ជួបគ្នា ស្គាល់គ្នា ។ ហើយឈ្មោះនេះបានអញ្ជើញខ្លួនមកស្រុកខ្មែរ ដើម្បីនិយាយពីការងារ ។ ខ្លួនចង់ស្គាល់មនុស្សដើម្បីរកការងារឲ្យបានច្បាស់លាស់ ។ ខ្លួនមានកូន ២ នាក់ ។ ខ្លួនបានជជែកគ្នាតាម Website រយៈពេល ៦ ខែ គាត់បានហៅខ្លួន តែខ្លួនបដិសេធ ។ មុនពេលមកកម្ពុជា ក៏ខ្លួនសួរពត៌មានដែរដូចជា PassPort ជាដើម ខ្លាចចាញ់បោកគេ ។ ខ្លួនបានជឿ ក៏មកកម្ពុជា ពេលមកដល់ខ្លួនមានអារម្មណ៍រំភើប ។ ពេលមកដល់ គាត់បាននាំខ្លួនទៅលេងខេត្តកំពត ។ ដោយខ្លួនយល់ឃើញថា គាត់ជាមនុស្សល្អដែរ ក៏ខ្លួនទុកចិត្ត ។ ក្រោយមកខ្លួនបានត្រឡប់ទៅវិញ បាន ២ ទៅ ៣ ថ្ងៃ ខ្លួនបានទាក់ទងគ្នាតាម Website ។ ពេលមកកម្ពុជា ដើម្បីជួបគាត់ តើគាត់ជាមនុស្សល្អមែនឬទេ ហើយខ្លួនជឿថាគាត់ល្អមែន ពេលជួបគាត់ ។ ពេលមកដល់កម្ពុជា ខ្លួនជាអ្នកចំណាយ ហើយគាត់ជាអ្នកចេញសំបុត្រយន្តហោះ ។ ខ្លួនចាយវាយនៅស្រុកខ្មែរ អស់ ៥០០ដុល្លាអាមេរិក ។ ពេលត្រឡប់ទៅវិញ គាត់មិនបានឲ្យអ្វីខ្លួនទេ ។ ពេលខ្លួនជួប

គាត់នៅកម្ពុជា បុរសនោះប្រាប់ខ្លួនថា គាត់រកស៊ីខាងនាំចេញ នាំចូល ទូរស័ព្ទ និង គ្រឿងហ្គេម និងគ្រឿងអេឡិចត្រូនិច ។ ពេលនោះខ្លួនជឿគាត់ថារកស៊ីមែនដោយគាត់មានភ្នាក់ងារនៅអូស្ត្រាលី ។ មូលហេតុដែលខ្លួនមកកម្ពុជាលើកទី២ ដោយសារបុរសនោះសុំខ្លួនមកធ្វើការជាម្ចាស់ហាងលក់គ្រឿងសិល្បៈ ម្ចាស់ហាងជាមិត្តភក្តិមេគាត់ ។ ពេលខ្លួនមកអូស្ត្រាលី ខ្លួនដើរទៅរកជួលហាង បើបើកហាងអូស្ត្រាលី អស់តម្លៃប៉ុន្មាន ។ ខ្លួនមានបង្រៀនកូនក្មេងនៅអូស្ត្រាលី គឺនៅតាមផ្ទះ ។ ពេលមកលើកទី២ គឺពិភាក្សាពីលក្ខខណ្ឌការងារជាមួយបុរសនោះ មាន ឯកសារ ៤ ទំព័រ ។ ពេលនោះបុរសនោះឲ្យលុយខ្លួនចំនួន ១០០០ ដុល្លាអាមេរិក ថ្លៃមកស្រុកខ្មែរ ថ្លៃចំណាយផ្សេងៗ ហើយសំបុត្រយន្តហោះ គឺបុរសនោះអ្នកចេញឲ្យ មកលើកទី២ បានជួបឈ្មោះ ហ្សាលីន ។ មកលើកទី២ ខ្លួនចុះកិច្ចសន្យាការងារហើយ ។ ប្រាក់ខែ គាត់សន្យាឲ្យខ្លួន គឺ ១៥០០ ដុល្លាអាមេរិក ទៅ១៦០០ ដុល្លាអាមេរិក តែមិនទាន់កាត់ពន្ធ ។ ពេលខ្លួនទៅលើកទី២ គាត់ជូនទៅពេទ្យ គាត់ឲ្យកាបូបមានរូបចម្លាក់បួន ធ្វើពីឈើ បានកាន់ហើយដាក់ចូលវ៉ាលី គាត់ផ្តាំឲ្យឈ្មោះ អេឡិច ដោយមានលេខទូរស័ព្ទ ។ គេទាញបង្ហាញរូបចម្លាក់ក្នុងវ៉ាលី ហើយគេដាក់ចូលវិញ មិនចាប់អារម្មណ៍ទេ ។ ពេលទៅដល់ព្រលានយន្តហោះមានគេឆែកម៉ាស៊ីនដែរ តែមិនមានអ្នកថាអីទេ មិនមានគ្រឿងញៀនទេ ។ ពេលនោះអេឡិច បានមករកខ្លួន ដើម្បីយកកាបូបនោះ ហើយមិនបានឲ្យលុយអ្វីមកខ្លួនទេ ។ ខ្លួនមានទំនាក់ទំនងត្រឹមជាមិត្តភក្តិប៉ុណ្ណោះ ។ ពេលខ្លួនឈឺត្រចៀក នៅស្រុកខ្មែរ ។ ខ្លួនប្រគល់ប្រាក់កក់ឲ្យគេហើយ តែមិនទាន់មានកុងត្រាទេ ។ ពេលមកលើកទី៣ ដើម្បីបញ្ជាក់លើលិខិតស្នាមកិច្ចសន្យាដោយលុយ ២០.០០០ (ពីរម៉ឺនដុល្លាអាមេរិក) ខ្លួនមិនទាន់បានទទួលទេ ។ ពេលនោះខ្លួនមិនចង់មកទេ តែត្រូវមកដើម្បីបញ្ជាក់រឿងកិច្ចសន្យា ។ ពេលមកលើកទី៣ ហ្សាលីន ជាអ្នកចំណាយ និងសំបុត្រយន្តហោះ ។ ហ្សាលីន គាត់ជាអ្នកទិញកាបូបឲ្យ តែខ្លួនមិនដឹងថាអ្នកណារៀបកាបូបទេ ផ្ញើរកាបូបឲ្យទៅឈ្មោះ ចន ។ ក្នុងកាបូបនោះមានអំបោះក្រណាត់ប៉ាក់មិនមានអ្វីទៀតទេ ខ្លួនជាអ្នកស្ពាយឡើងយន្តហោះ ដោយខ្លាចបាត់របស់គេផ្ញើរ ។ ពេលចាប់ខ្លួន គេវះកាបូបទើបឃើញមានគ្រឿងញៀនមែន ។ ហ្សាលីន ត្រូវចាប់ខ្លួនដែរ ។ ខ្លួនមិនបានចាប់អារម្មណ៍ ថាកាបូបនោះធ្ងន់ទេ ព្រោះពេលនោះខ្លួនឈឺ ។ គ្រឿងញៀនមានចំនួន ២ គីឡូ ។ ពេលស្ពាយកាបូប មិនមានអារម្មណ៍ទើសទេ ព្រោះកាបូបមានទ្រនាប់ ។ ខ្លួនខំប្រឹងការពារខ្លួន និងខំប្រឹងមើលដែរ តែនៅតែចាញ់បោកគេ ចាត់ទុកថាខ្លួនល្ងង់ចុះ ។ កាបូបនោះ ទាល់តែវះបានដឹង ខ្លួនមិនអាចមើលឃើញទេ ។ មកស្រុកខ្មែរ និយាយរឿងការងារពីកុមារកំព្រា ខ្លួនគិតថាគាត់ជាអ្នកជួយមនុស្សធម៌ ។ ខ្លួនបដិសេធរឿងស្នេហាជាមួយគាត់ ដោយគាត់ក្មេងពេក ។

-តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋានថា: តុលាការកំពូលបានចង្អុលបង្ហាញតាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ ពីចេតនាប្រព្រឹត្តបទល្មើស ។ ឧក្រិដ្ឋជនគ្រឿងញៀនមានលក្ខណៈប៉ិនប្រសប់ ។ សូមក្រុមប្រឹក្សាពិចារណាពីចេតនា របស់ជនជាប់ចោទ ថេល័រ យូសេ អាន តាមការចង្អុលបង្ហាញរបស់តុលាការកំពូល ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា: របាយការណ៍ប៉ូលីស បានបញ្ជាក់ថា កូនក្ដីខ្លួនជាជនរងគ្រោះ ។ ដូច្នេះ តុលាការមិនដាក់ទោសជនរងគ្រោះ ។ ការសន្និដ្ឋានតំណាងមហាអយ្យការនៅតុលាការកំពូល ក៏បានសន្និដ្ឋានថា កូនក្ដីខ្លួនជាជនរងគ្រោះដែរ ។ តំណាងមហាអយ្យការនៅសាលាឧទ្ធរណ៍ក៏បានសន្និដ្ឋាន ជនជាប់ចោទ ថេល័រ យូសេ អាន ជាជនរងគ្រោះដែរ និងមានរបាយការណ៍ប៉ូលីសខ្មែរ បញ្ជាក់ថា កូនក្ដីខ្លួនជាជនរងគ្រោះដែរ ។ សំណូមពរ សុំផ្ដល់យុត្តិធម៌ដល់កូនក្ដី ដែលជាជនរងគ្រោះ សុំលើកលែងចោទប្រកាន់ដើម្បីទៅមើលកូន ២នាក់ ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

- ក្រោយពីបានពិចារណាលើគ្រប់ឯកសារ និងភស្ដុតាងផ្សេងៗ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ ។

## **សំអាងហេតុ**

## **យល់ឃើញថា**

១-តុលាការកំពូលបានសម្រេចបង្វិលសំណុំរឿងព្រហ្មទណ្ឌនេះ មកឲ្យសាលាឧទ្ធរណ៍ជំនុំជម្រះឡើងវិញតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ៣១៨ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០១៨ របស់តុលាការកំពូល ។ សាលឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន តាមមាត្រា ៤៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-តាមសាលដីកាព្រហ្មទណ្ឌលេខ ៣១៨ ចុះថ្ងៃទី១៣-០៧-២០១៨ របស់តុលាការកំពូល បានចង្អុលបង្ហាញឲ្យសាលាឧទ្ធរណ៍ពិចារណាដូចខាងក្រោម ៖

២-១-ពីធាតុចេតនារបស់ពិរុទ្ធជន ឈ្មោះ Taylor [redacted] ថាតើមានអត្ថិភាព ឬនត្ថិភាពនៃធាតុផ្សំអត្តនោម័ត ចំពោះករណីពិរុទ្ធជនឈ្មោះ ថេល័រ ដោយតុលាការកំពូលយល់ឃើញថា ការដែលសាលាឧទ្ធរណ៍ជំនុំជម្រះ លើកទី១ ដោយសំអាងថា ថ្នាំញៀន ត្រូវបានដកហូតពីជនជាប់ចោទឈ្មោះ ថេល័រ ដាក់ស្ដែងនៅព្រលានយន្តហោះ ហើយសន្និដ្ឋានថា មាន

ពិរុទ្ធភាព លើជនជាប់ចោទ ថេល័រ នេះពីបទ ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន នោះគឺនៅមិនទាន់មានមូលដ្ឋានគ្រប់គ្រាន់នៅឡើយទេ ។

២-២- តុលាការកំពូល បានចង្អុលបង្ហាញថា សាលាឧទ្ធរណ៍ជំនុំជម្រះលើកទី១ នៅមិនទាន់បានលើកយកមកពិចារណានូវរបាយការណ៍ ចុះថ្ងៃទី២២-០៩-២០១៣ របស់ការិយាល័យប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន នៃនាយកដ្ឋានប្រឆាំងគេរវកម្មនៃក្រសួងមហាផ្ទៃ ដែលគូសបញ្ជាក់ថា "ឈ្មោះ Taylor [redacted] អាចជាអ្នកចាញ់កលល្បិចដ៏ប៉ិនប្រសប់របស់ឈ្មោះ Nwoko [redacted] និងចម្លើយរបស់លោក [redacted] ជាមន្ត្រីនគរបាល ដែលថាគ្រឿងញៀនដាក់ក្នុងជញ្ជាំងកាបូប មើលនឹងភ្នែកពុំអាចដឹងទេ" ។

២-៣- តុលាការកំពូលក៏បានលើកឡើងនូវរបាយការណ៍ ចុះថ្ងៃទី២២-០៩-២០១៣ របស់ការិយាល័យប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន នៃនាយកដ្ឋានប្រឆាំងគេរវកម្មនៃក្រសួងមហាផ្ទៃ ដែរថា : ការស៊ើបអង្កេតឈានទៅដល់ការចាប់ខ្លួនជនជាប់ចោទក្នុងរឿងក្តីនេះ គឺដោយសារតែការចាប់ខ្លួនជនជាតិអូស្ត្រាលី ពីររូបឈ្មោះ Cathryn [redacted] និងឈ្មោះ David [redacted] Douglas ដែលត្រូវបានឈ្មោះ អ៊ិនវូកូ និងឈ្មោះ សារ៉ាវីណ្ហ ហ្សាលីន ផ្ញើវ៉ាលី និងកាបូបស្ពាយចំនួន ៤ ដោយមានលាក់គ្រឿងញៀន ហើយត្រូវចាប់ខ្លួននៅប្រទេសអូស្ត្រាលី ។ ហើយមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ ថេល័រ បានផ្តល់ឯកសារពាក់ព័ន្ធ នឹងការសម្រេចឲ្យរួចខ្លួនលើឈ្មោះ David [redacted] និងប្រតិចារិក ក្នុងរឿងក្តីរបស់ឈ្មោះ David [redacted] ដែលជាមូលដ្ឋានឲ្យសាលាឧទ្ធរណ៍ ធ្វើការពិចារណាបន្ថែម ។ ក្រុមប្រឹក្សាសាលាឧទ្ធរណ៍ គប្បីពិចារណាតាមការចង្អុលបង្ហាញរបស់តុលាការកំពូល ។

៣-តាមរបាយការណ៍ ចុះថ្ងៃទី ២២-០៩-២០១៣ (ឯកសារលេខ ១ ) របស់ការិយាល័យប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន នៃនាយកដ្ឋានប្រឆាំងគេរវកម្ម នៃក្រសួងមហាផ្ទៃ ដែលគូសបញ្ជាក់ថា Taylor [redacted] អាចជាអ្នកចាញ់កលល្បិចដ៏ប៉ិនប្រសប់របស់ឈ្មោះ អ៊ិន វូកូ ព្រីហ្សីស ឈីនីមេ និងតាមចម្លើយបំភ្លឺរបស់លោក គង់ ណារិទ្ធិ (ឯកសារលេខ ៥ និងលេខ ១០១/១៣) ជាមន្ត្រីនគរបាលដែលឆ្លើយបំភ្លឺនៅសវនាការសាលាដំបូងរាជធានីភ្នំពេញថា គ្រឿងញៀនដាក់ក្នុងជញ្ជាំងកាបូបមើលនឹងភ្នែកពុំអាចដឹងទេ.... ការដាក់នោះគឺប្រើម៉ាស៊ីនដេរជំនាញទើបអាចធ្វើបាន មានលក្ខណៈស៊ីសង្វាក់គ្នា នឹងចម្លើយរបស់ពិរុទ្ធជនឈ្មោះ Taylor [redacted] ដែលបានឆ្លើយបំភ្លឺតាំងពីសាលាដំបូងរហូតដល់តុលាការកំពូល និងនៅសាលាឧទ្ធរណ៍ ជំនុំជម្រះ លើកទី២ នេះប្រហាក់ប្រហែលគ្នាថា: ខ្លួនស្គាល់ឈ្មោះ អ៊ិន វូកូ ព្រីហ្សីស តាមរយៈ Internet គឺ website Tagg-ID ជា website ជជែកគ្នារកដៃគូរសង្សា ក្រោយមកក្នុងអំឡុងខែ ៦ ,

៧ Precious បានឲ្យមកជួបនៅកម្ពុជា ។ មុនមកពិរុទ្ធជនរូបនេះ បានឲ្យជនជាប់ចោទឈ្មោះ Precious ផ្ញើ Passport , Email ទើបស្គាល់ថា ជាឈ្មោះ Precious [redacted] ក៏បានទំនាក់ទំនងគ្នារាប់អានគ្នា មកស្រុកខ្មែរ ដើរលេងទៅកំពត ដោយឈ្មោះ Precious ជាអ្នកចេញចំណាយហូបចុក Hotel ទើបខ្លួនជឿថាឈ្មោះ Precious ជាមនុស្សល្អ តែក្មេងពេក ។ ឈ្មោះ Taylor បានត្រឡប់ទៅអូស្ត្រាលី វិញ មិនទាន់ផ្ញើវ៉ាន់ទេ ។ ឈ្មោះ Precious ប្រាប់ថា គាត់រកស៊ី នាំចេញ-នាំចូល គ្រឿង Electronic ដូចជា Phone ,Game ពី អូស្ត្រាលី ពេលនោះ គាត់មិនទាន់និយាយពីការងារទេ ។ លើកទី២ Precious បានជជែកពីការផ្តល់ការងារមកឲ្យខ្លួន ធ្វើការនៅហាងលក់វត្ថុសិល្បៈខ្មែរ ដែលម្ចាស់ជាខ្មែរ សញ្ជាតិអូស្ត្រាលី ជាមិត្តរបស់គាត់ឲ្យប្រាក់ខែ ១០០០ ដុល្លាអាមេរិក ក្នុងមួយខែ ។ មុនពេលឡើងមកកម្ពុជាលើកទី២ ខ្លួនបានដើររកមើលហាងដើម្បីជួល ។ ខ្លួនមកកម្ពុជាលើកទី២ ដើម្បីចុះកិច្ចសន្យាការងារ តែមិនទាន់បានទទួលប្រាក់ខែ ឬប្រាក់ដើម្បីយកទៅកក់ហាង នៅ អូស្ត្រាលី ទេ លើកទី២ នេះ ខ្លួនឈឺត្រចៀក ឈ្មោះ Precious បាននាំទៅពេទ្យត្រចៀក រួចបានស្នើសុំផ្ញើកាបូប ១តាមខ្លួន ទៅឲ្យមិត្តគាត់នៅ New South Wale កាបូបនោះមានរូបចម្លាក់ ៤ ធ្វើពីឈើ ។ ផ្ញើទៅឈ្មោះ Alexនៅ New South Wale លើកនេះ មិនបានពិនិត្យកាបូបទេ ព្រោះកាបូបនេះ ដាក់ក្នុង Suitcase វ៉ាលីស ទៅដល់អូស្ត្រាលី Alex មកទទួលនៅកន្លែង Shopping Center ខ្លួនក៏បានប្រាប់ Precious ថាបានឲ្យកាបូបនោះទៅ Alex ហើយ ។ លើកទី៣ Precious បានឲ្យខ្លួនមកកម្ពុជាម្តងទៀត ដើម្បីយកលុយកក់ហាងនៅអូស្ត្រាលី និងកែប្រែកិច្ចសន្យាការងារខ្លះ ព្រោះហាងនៅ អូស្ត្រាលី គេប្រាប់ថាឈប់ជួលឲ្យហើយ ហើយឡើងថ្ងៃទៀត Precious បានប្រាប់ថា ត្រូវឡើងមកកម្ពុជា ដើម្បីផ្តិតស្នាមមេដៃ លើឯកសារ ពីពេលនោះខ្លួនឈឺពោះ មិនចង់មកកម្ពុជាទេ តែគ្មានជម្រើស ក៏មកលើកទី៣ ថ្ងៃទី១៦-០៩-២០១៣ មកជួប Precious និង Charlene បានយកកាបូបមួយដែល Precious ផ្ញើរទៅ អូស្ត្រាលី មកដល់ Hotel ខ្លួនហើយ Charlene ជូនខ្លួនទៅព្រលានយន្តហោះដោយ Precious ប្រាប់ថាមិនបានជូនទេ ជាប់រវល់ទៅថៃ ។ ពេលទទួលកាបូបស្ពាយនោះ ខ្លួនបានពិនិត្យមើល និងថតទុកដែរ ព្រោះខ្លាចបាត់របស់គេដែលគេផ្ញើរ ។ កាបូបនេះមិនដាក់ក្នុង suitcase ទេ គឺខ្លួនស្ពាយ ហើយខ្លួនក៏មានអារម្មណ៍ថា ធ្ងន់ដែរ តែមិនចាប់អារម្មណ៍ ព្រោះនឹកស្មានថាប្រហែលខ្លួនឈឺ ទើបមានអារម្មណ៍ថាធ្ងន់ ។ ពេលខ្លួនបើកកាបូបនោះពិនិត្យ និងថតទុកនោះគ្មានឃើញគ្រឿងញៀនទេ ឃើញតែក្រណាត់ប៉ាក់ ។ តាមចម្លើយរបស់ពិរុទ្ធជនឈ្មោះ Taylor និងរបាយការណ៍របស់ការិយាល័យប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ចុះថ្ងៃទី២២-០៩-២០១៣ ខាងលើ និងការបំភ្លឺរបស់មន្ត្រី គង់ ណារិទ្ធិ អាចឲ្យក្រុមប្រឹក្សាពិចារណាឃើញថា នៅមានវិមតិ

សង្ស័យ លើជាតុផ្សំអត្តនោម័ត របស់ពិរុទ្ធជនឈ្មោះ Taylor [redacted] លើការដឹងថាក្នុងកាបូបស្ពាយដែល Precious ផ្ញើទៅអូស្ត្រាលីនេះ មានលាក់ទុកគ្រឿងញៀននោះ ។ ហេតុនេះ វិមតិសង្ស័យ ជាប្រយោជន៍ដល់ពិរុទ្ធជនរូបនេះ តាមមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ , មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។ គប្បីឲ្យពិរុទ្ធជនរូបនេះ រួចផុតពីបទចោទប្រកាន់ ព្រោះ Taylor មិនបានដឹង គ្មានចេតនាប្រព្រឹត្តបទល្មើស ដឹកជញ្ជូនគ្រឿងញៀនឆ្លងដែនទេ តាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ ថា ពុំមានបទល្មើសទេ បើគ្មានចេតនាប្រព្រឹត្ត ។

៤-ក្រុមប្រឹក្សាយល់ឃើញថា យោងតាមរបាយការណ៍លេខ ១៣១ សណ/១៣ ចុះថ្ងៃទី ២២-០៩-២០១៣ របស់ការិយាល័យប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែននៃនាយកដ្ឋានប្រឆាំងគេវរកម្ម នៃក្រសួងមហាផ្ទៃ ដែលបានបញ្ជាក់ពីដំណើររឿងថា ការិយាល័យប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន បានទទួលរបាយការណ៍ និងបើកការស៊ើបអង្កេតការនាំគ្រឿងញៀន ហេរ៉ូអ៊ីនចូលអូស្ត្រាលី ចំនួនពីរករណី នៅថ្ងៃទី២៩-០៨-២០១៣ ចំនួន ៨ គីឡូក្រាម ដោយស្ត្រីជនជាតិអូស្ត្រាលី ឈ្មោះ Cathryn [redacted] (អាយុ ៤៤ឆ្នាំ) និងបុរសជនជាតិអូស្ត្រាលីម្នាក់ទៀតឈ្មោះ David [redacted] អាយុ៤២ឆ្នាំ) ។ ពួកគេទាំងពីរនាក់ធ្លាប់មកក្រុងភ្នំពេញជួបឈ្មោះ Precious និងឈ្មោះ Charlene [redacted] ដែលត្រូវជាមិត្តភក្តិស្គាល់គ្នាតាម Online ។ មួយថ្ងៃមុនពេលចាកចេញ ឈ្មោះ Precious និង ឈ្មោះ Charlene បានឲ្យវ៉ាលី និងកាបូបស្ពាយចំនួន ០៤ ទៅជនជាតិអូស្ត្រាលីទាំង២នាក់ យកទៅអូស្ត្រាលី ហើយត្រូវបានឆែកឆេរឃើញគ្រឿងញៀន លាក់នៅកាបូបកុំព្យូទ័រយួរដៃចំនួន ៤ ហើយត្រូវចាប់ខ្លួន ។ តាមរយៈការស៊ើបអង្កេតបញ្ជាក់ថា ថ្ងៃទី១៥-០៩-២០១៣ ស្ត្រីអូស្ត្រាលីម្នាក់ឈ្មោះ Taylor [redacted](អាយុ២១ឆ្នាំ) បានចូលមកកម្ពុជាស្នាក់នៅសណ្ឋាគារ ខាក់ សង្កាត់ស្រះចក ។ ឈ្មោះ Charlene បានទាក់ទងនឹងនាំ Taylor ដើរលេងចូលភោជនីយដ្ឋាន និងឲ្យកាបូបស្ពាយពណ៌ខ្មៅ ទំហំប្រហែល ៤០ cm× ៧០cm នៅព្រឹកថ្ងៃទី១៨-០៩-២៥១៣ នៅសណ្ឋាគារ ខាក់ ទៅស្ត្រីឈ្មោះ Taylor [redacted] ។ តាមលទ្ធផលនៃការស៊ើបសង្កេត ខាងលើនេះក៏ដូចចម្លើយពិរុទ្ធជន Taylor [redacted] ស៊ីសង្វាក់គ្នានឹងចម្លើយទណ្ឌិតឈ្មោះ Savarino [redacted] និងឈ្មោះ Precious [redacted] ដែលបានបញ្ជាក់ច្បាស់ថា ឈ្មោះ Charlene ត្រូវបានឈ្មោះ Precious ណែនាំឲ្យស្គាល់ពិរុទ្ធជនឈ្មោះ Taylor ថ្ងៃទី១៥-០៩-២០១៣ តាមរយៈរូបថតក្នុងទូរសព្ទដៃនៅផ្ទះ Precious លេខ ១៧B ហើយឈ្មោះ NTO មិត្តរបស់ឈ្មោះ Precious ឲ្យឈ្មោះ Charlene ទៅទទួលឈ្មោះ Taylor នៅព្រលានយន្តហោះភ្នំពេញ មកស្នាក់នៅសណ្ឋាគារ ខាក់ តម្លៃមួយយប់ ៦៧ ដុល្លារអាមេរិក (Charlene អ្នកបង់លុយឲ្យ) នៅថ្ងៃដដែល Precious បានទៅជួបឈ្មោះ Taylor នៅសណ្ឋាគារ

។ ថ្ងៃទី១៦-១៧-កញ្ញា-២០១៣ Charlene បាននាំ Taylor ទៅចូលហាង Sofitel ធ្វើសក់ និង ក្រចក ។ ថ្ងៃទី១៨-០៩-២០១៣ ម៉ោង ១១ និង ៣០នាទី ព្រឹក Charlene ចេញពីផ្ទះរបស់ Precious យកកាបូបស្ពាយមួយពណ៌ខ្មៅ ទៅសណ្ឋាគារខារ៉ា ឲ្យទៅ Taylor (Precious និង NTO ជាអ្នកឲ្យ Charlene យកទៅឲ្យ) នៅម៉ោង ៦.០០ ល្ងាច ឈ្មោះ Charlene ជិះតាក់ស៊ីទៅ សណ្ឋាគារខារ៉ា នាំ Taylor ទៅព្រលានយន្តហោះ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន ។ រីឯចម្លើយទណ្ឌិត Precious [redacted] ថា ខ្លួនបានឲ្យកាបូបស្ពាយពណ៌ខ្មៅ មួយទៅ Charlene យកទៅឲ្យ Taylor នាំទៅអូស្ត្រាលីប្រគល់ឲ្យឈ្មោះ Jonh កាបូបនោះខ្លួនទទួលពីឈ្មោះ Martish [redacted] ហៅ NTO ហើយខ្លួនធ្លាប់ផ្ញើរកាបូបដៃ និងកាបូបស្ពាយចំនួន ០៦ លើកក្នុងនោះផ្ញើតាមរយៈ Dave និង Cathy ម្នាក់ចំនួន ២ កាបូប និងលើកទី០៦ ថ្ងៃទី១៨-០៩-២០១៣ ខ្លួនបានឲ្យ Charlene យកកាបូបស្ពាយទៅឲ្យ Taylor នៅសណ្ឋាគារ ខារ៉ា ។ ដោយយោងតាមរបាយការណ៍ និងចម្លើយរបស់ពិរុទ្ធជន និងទណ្ឌិតទាំងអស់ ខាងលើបង្ហាញឲ្យក្រុមប្រឹក្សាជឿបានថា កាបូបស្ពាយពណ៌ខ្មៅដែលមានលាក់នូវគ្រឿងញៀនក្នុងនោះ ហើយពិរុទ្ធជន Taylor ជាអ្នកស្ពាយឡើងយន្តហោះនោះ មិនមែនជារបស់ពិរុទ្ធជនឈ្មោះ Taylor ទេ ហើយក៏មិនបានរៀបចំទុកដាក់ដោយឈ្មោះ Taylor នោះដែរ ផ្ទុយទៅវិញ ជារបស់ក្រុមឧក្រិដ្ឋជនឈ្មោះ Martish [redacted] ហៅ NTO និងឈ្មោះ Savarino [redacted] ដែលធ្លាប់ប្រើល្បិចឆបោកផ្ញើកាបូបយួរដៃទៅអូស្ត្រាលីតាមរយៈ David [redacted] និងឈ្មោះ Cathryn [redacted] ចំនួន ០៤ ទៅអូស្ត្រាលី ហើយដែលជនជាតិអូស្ត្រាលីឈ្មោះ David [redacted] និងឈ្មោះ Cathryn [redacted] ខាងលើនេះ ត្រូវបានរដ្ឋអាជ្ញានៃតុលាការប្រទេសអូស្ត្រាលី ទំលាក់ បទចោទប្រកាន់ និងឲ្យរួចខ្លួនវិញនោះ ជាអ្នករៀបចំផ្ញើកាបូបស្ពាយពណ៌ខ្មៅ តាមពិរុទ្ធជនឈ្មោះ Taylor [redacted] នៅថ្ងៃទី១៨-០៩-២០១៣ ទៅអូស្ត្រាលី ។

តាមអង្គហេតុ និងកាលៈ ទេសៈនៃដំណើរការប្រព្រឹត្តបទល្មើស ខាងលើនេះក្រុមប្រឹក្សាយល់ថា ពិរុទ្ធជនឈ្មោះ Taylor [redacted] មិនបានដឹង និងមិនអាចដឹងបានទេ ថាកាបូបស្ពាយពណ៌ខ្មៅ ដែលក្រុមឧក្រិដ្ឋជនបានផ្ញើតាមខ្លួនទៅអូស្ត្រាលីនោះមានគ្រឿងញៀនបង្កប់ក្នុងខ្នងកាបូបពីព្រោះថា ពិរុទ្ធជនមិនមែនជាម្ចាស់កាបូប និងបានរៀបចំកាបូបនេះដោយខ្លួនឯងទេ តែជាកាបូបដែលរៀបចំដោយក្រុមឧក្រិដ្ឋជនយកមកផ្ញើឲ្យពិរុទ្ធជនឈ្មោះ Taylor [redacted] ទៅអូស្ត្រាលី ម្យ៉ាងទៀតតាមការបញ្ជាក់របស់លោក គង់ ណារិទ្ធិ មន្ត្រីនគរបាលបញ្ជាក់ថា កាបូបនេះ បើបើកមើលនឹងភ្នែកមិនអាចដឹងថាមានគ្រឿងញៀនបង្កប់ក្នុងនោះទេ ព្រោះគ្រឿងញៀនត្រូវគេវះដាក់ក្នុងខ្នងកាបូប រួចដេរទៅវិញដោយម៉ាស៊ីនជំនាញ ។ តាមចម្លើយរបស់ពិរុទ្ធជន

Taylor [redacted] បញ្ជាក់ថា ខ្លួនក៏បានបើកកាបូប ដែលផ្ញើនោះមើល និងថតទុកដែល ព្រោះខ្លាចបាត់របស់ដែលគេផ្ញើ ប៉ុន្តែខ្លួនមិនបានឃើញគ្រឿងញៀនទេ នេះមានន័យថា ពិរុទ្ធជនមិនបានដឹងនិងគ្មានចេតនាប្រព្រឹត្តបទល្មើសដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀនឆ្លងដែនទេ ។ ម្យ៉ាងទៀត ក្នុងការទទួលបញ្ញើកាបូបស្ពាយពីក្រុមឧក្រិដ្ឋជនទៅអូស្ត្រាលីនេះ ពិរុទ្ធជនឈ្មោះ Taylor [redacted] គ្មានបានទទួលអត្ថប្រយោជន៍លុយកាក់អ្វីទេ គឺគ្រាន់តែក្រុមឧក្រិដ្ឋជនជួយចេញថ្លៃចំណាយសំបុត្រយន្តហោះ និងថ្លៃសណ្ឋាគារ តែប៉ុណ្ណោះ ។ នេះក៏អាចបញ្ជាក់ថា បើពិរុទ្ធជន Taylor [redacted] មានចេតនាប្រព្រឹត្តបទល្មើសមែននោះ ពិរុទ្ធជនរូបនេះ ពិតជានឹងទទួលបានចំណែកថ្លៃសេវាបញ្ញើនេះ ក្នុងតម្លៃសមស្របណាមួយ ហើយប៉ុន្តែក្នុងរឿងក្តីនេះពិរុទ្ធជនឈ្មោះ Taylor [redacted] បានមកកម្ពុជាចំនួន ៣ លើក ជួបឈ្មោះ Precious និងឈ្មោះ Charlene ប៉ុន្តែឈ្មោះ Taylor [redacted] មិនដែលបានទទួលប្រាក់ ឬ អត្ថប្រយោជន៍ ដ៏មានតម្លៃសមស្របណាមួយ ថាជូននឹងការទទួលយកបញ្ញើកាបូបទៅអូស្ត្រាលីទេ ។

៩-មេធាវីការពារសិទ្ធិឲ្យពិរុទ្ធជន Taylor [redacted] បានលើកឡើងនូវរឿងក្តី លោកស្រី Cathryn [redacted] យោងតាមឯកសារ (សេចក្តីសម្រេចនៃរដ្ឋអាជ្ញាតុលាការ In The County Court of Victoria at MELBOURNE No.CR-14-00246 ចុះថ្ងៃទី២៦-០៣-២០១៥) និងរឿងក្តី David [redacted] យោងឯកសារ (របាយការណ៍នៃការចោទប្រកាន់ របស់ប្រធានរដ្ឋអាជ្ញា នៃរដ្ឋសហជន ទីក្រុង Perth ចុះថ្ងៃទី២៧-១១-២០១៤) ដែលត្រូវតុលាការប្រទេសអូស្ត្រាលី បានសម្រេចឲ្យរួចខ្លួន ពីបទចោទប្រកាន់ដោយសារចាញ់កលល្បិចបោកបញ្ឆោតរបស់ក្រុមឧក្រិដ្ឋជន Nwoko [redacted]និងរឿងក្តីលោកស្រី Yoshe [redacted]មានលក្ខណៈដូចគ្នា ។ ការលើកឡើងនេះ ស្របនឹងភស្តុតាងជាឯកសាររបស់តុលាការ County court Of Victoria at Melbourne និងរបាយការណ៍នាយករដ្ឋអាជ្ញា CommonWealth បានសម្រេចឲ្យ David [redacted] រួចខ្លួន ។ ទោះបី មានភស្តុតាងលើការសម្រេចឲ្យជនជាប់ចោទទាំងពីររូបរួចខ្លួនរបស់រដ្ឋអាជ្ញា និងតុលាការអូស្ត្រាលី ក៏ដោយ ក៏ សេចក្តីសម្រេចរបស់ប្រទេសអូស្ត្រាលី មិនមែនជាចំណងកាតព្វកិច្ចដល់សាលាឧទ្ធរណ៍កម្ពុជា សម្រេចតាមនោះ ព្រោះកម្ពុជាមិនមែនជាសមាជិកនៃប្រទេស CommonWealth ទេ ហើយសាលាឧទ្ធរណ៍កម្ពុជា មានអធិបតេយ្យភាពពេញលេញ ក្នុងការពិចារណា និងសម្រេចតាមច្បាប់ ភស្តុតាង កម្ពុជា ប៉ុន្តែទោះយ៉ាងនេះក្តី ក៏រឿងក្តីនេះមានចំណងទាក់ទងនឹងក្រុមឧក្រិដ្ឋជន Precious តែមួយ ដែលធ្លាប់ប្រើកលល្បិចដាក់ជនជាប់ចោទក្នុងរឿងក្តីនៅប្រទេសអូស្ត្រាលី ហើយយករូបភាព មធ្យោបាយបោកបញ្ឆោតដដែលមកអនុវត្តលើពិរុទ្ធជន Taylor ទៀត ។ ម្យ៉ាងទៀតការចាប់និងបញ្ជូនក្រុមឧក្រិដ្ឋ

ដូរគ្រឿងញៀនឆ្លងដែន Precious នេះក៏ដោយសារការឃាត់ចាប់ខ្លួនលោកស្រី Cathryn [redacted] និងលោក David [redacted] ទើបមានការចាប់ខ្លួន Precious និងបក្សពួក Charlene បាន ដែលអាចឲ្យក្រុមប្រឹក្សាពិចារណាយកជាមូលដ្ឋានបានក្នុងការពិចារណា និងសម្រេច ចំពោះរឿងក្តីលោកស្រី Taylor [redacted] នេះ ។

៦-តំណាងមហាអយ្យការផ្ញើសេចក្តីសន្និដ្ឋាន ជាលាយល័ក្ខណ៍អក្សរ ថា: យល់ឃើញថាតុលាការកំពូលបានសម្រេចតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ត្រង់ចំណុច តម្កល់សាលក្រមរបស់សាលាដំបូងពាក់ព័ន្ធនឹងការផ្តន្ទាទោសលើជនជាប់ចោទ អិនវូកូ ព្រីហ្វីស ឈីនីមេ ប៉ុន្តែបដិសេធចំណុចពាក់ព័ន្ធនឹងការផ្តន្ទាទោសលើជនជាប់ចោទ ថេល័រ យូសេ អាន ដោយលើកឡើងថា សាលាឧទ្ធរណ៍មិនបានលើកយកមកពិចារណា នូវរបាយការណ៍ចុះថ្ងៃទី២២-០៩-២០១៣ របស់ការិយាល័យប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន នៃនាយកដ្ឋានប្រឆាំងគេរវកម្ម នៃក្រសួងមហាផ្ទៃ និងឯកសារ ដែលមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ថេល័រ បានដាក់ជូនតុលាការកំពូល ពាក់ព័ន្ធ នឹងការសម្រេចឲ្យខ្លួន លើឈ្មោះ David [redacted] និងប្រតិចារិក ក្នុងរឿងក្តីរបស់លោក David [redacted] និងឈ្មោះ Cathryn [redacted] ដែលអាចជាមូលដ្ឋានសម្រាប់ឲ្យសាលាឧទ្ធរណ៍ ពិចារណាបន្ថែម ពាក់ព័ន្ធ នឹងអត្ថិភាព ឬនត្ថិភាព នៃធាតុផ្សំអត្តនោម័ត ចំពោះពិរុទ្ធជន ថេល័រ យូសេ អាន ។

-សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់តំណាងអយ្យការ នាពេលសវនាការសាលាឧទ្ធរណ៍ថាតុលាការកំពូលបានចង្អុលបង្ហាញតាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ ពីចេតនាប្រព្រឹត្តបទល្មើស និងក្រុមឧក្រិដ្ឋជនគ្រឿងញៀនមានលក្ខណៈប៉ិនប្រសប់ ។ សុំក្រុមប្រឹក្សាពិចារណាពីធាតុចេតនា ថេល័រ តាមការចង្អុលបង្ហាញរបស់តុលាការកំពូល ។ គប្បីក្រុមប្រឹក្សាពិចារណា ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលជំនុំជម្រះ សំណុំរឿងព្រហ្មទណ្ឌលេខ ៩១៩ ចុះ០៦-០៨-២០១៨ របស់សាលាឧទ្ធរណ៍ មកជំនុំជម្រះបាន តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ៣១៨ ចុះថ្ងៃទី១៣-០៧-២០១៨ របស់តុលាការកំពូល និងតាមមាត្រា ៤៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-បដិសេធចោលសេចក្តីវិនិច្ឆ័យនៃសាលដីកាព្រហ្មទណ្ឌលេខ ១១៨ ក្រV បស ចុះថ្ងៃទី ០៦-១២-២០១៦ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចដែលសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌ

លេខ ៥០ កបប២ "ឆ" ចុះថ្ងៃទី២៨-០៥-២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច ១-គ នៃសេចក្តី សម្រេចនៃសាលក្រម ៥០កបប២ "ឆ" ចុះថ្ងៃទី២៨-០៥-២០១៤ ត្រង់ "ផ្តន្ទាទោស ឈ្មោះ Taylor [redacted] ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិអូស្ត្រាលី ដាក់ពន្ធនាគារកំណត់ ២៣ (ម្ភៃបី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០.០០០.០០០ (ហាសិបលាន) រៀល" ។ ចំណុចក្រៅពីនេះ រក្សាទុកជាបានការដដែល នូវសាលដីកាព្រហ្មទណ្ឌលេខ ១១៨ ក្រV បស ចុះថ្ងៃទី០៦-១២-២០១៦ របស់សាលាឧទ្ធរណ៍ ។

៣-ឲ្យឈ្មោះ Taylor [redacted] ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិអូស្ត្រាលី រួចផុតពីបទចោទប្រកាន់ពីបទ: **ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន (ឆ្លងដែន)** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ដល់ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤-បង្គាប់ឲ្យដោះលែងឈ្មោះ Taylor [redacted] ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិអូស្ត្រាលី (សាវតាជាតិដូចក្នុងសំណុំរឿង) ពីមន្ទីរអប់រំកែប្រែ បើឈ្មោះនេះមិនត្រូវជាប់ឃុំក្នុងបទល្មើសណាមួយផ្សេងទៀតទេ ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ ថ្ងៃទី២៧-០៣-២០១៩ ចំពោះមុខពិរុទ្ធជន មេធាវីការពារសិទ្ធិឲ្យពិរុទ្ធជន និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៩-០៤-២០១៩ ចំពោះមុខពិរុទ្ធជន និង ចំពោះមុខមេធាវីការពារសិទ្ធិឲ្យពិរុទ្ធជន ។

បើកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] , [redacted]<br>[redacted] , [redacted] | ហត្ថលេខា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃ អង្គារ ៤ រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០១៩
**ក្រឡាបញ្ជី**

[redacted]

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]